# សេចក្តីប្រកាសព័ត៌មាន

## សិក្ខាសាលាថ្នាក់តំបន់ ស្តីពី "ការត្រួតពិនិត្យផ្អែកលើហានិភ័យ សម្រាប់ទីផ្សារមូលធនអាស៊ានប្រកបដោយភាពធន់ បរិយាបន្ន និងចីរភាព"

ថ្ងៃចន្ទ ៣រោច និងថ្ងៃអង្គារ ៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ត្រូវនឹងថ្ងៃទី៨ និងថ្ងៃទី៩ ខែធ្នូ គ.ស.២០២៥ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា



នាថ្ងៃចន្ទ ៣រោច និងថ្ងៃអង្គារ ៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៨ និងថ្ងៃទី៩ ខែធ្នូ គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)** និយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) ក្នុងនាមជាសហប្រធានកម្មវិធីអភិវឌ្ឍន៍ទីផ្សារ (A-MDP) នៃវេទិកាទីផ្សារមូលធនអាស៊ាន (ACMF) និងក្រោមកិច្ចគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានរៀបចំសិក្ខាសាលាទម្រង់កូនកាត់ (Hybrid) ស្តីពី **"ការត្រួតពិនិត្យផ្អែកលើហានិភ័យសម្រាប់ទីផ្សារមូលធនអាស៊ានប្រកបដោយភាពធន់ បរិយាបន្ន និងចីរភាព"** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ **ន.ម.ក.** និងជាសហប្រធាន A-MDP, លោក Vu Chi Dzung អគ្គនាយកផ្នែកច្បាប់ និងកិច្ចការអន្តរជាតិ នៃគណៈកម្មការមូលបត្ររដ្ឋវៀតណាម និងជាសហប្រធាន A-MDP និងលោក Vijay Kumar Akasaam ប្រធានប្រតិបត្តិការបេសកកម្មប្រចាំប្រទេសកម្ពុជារបស់ ADB នៅសណ្ឋាគារ ហៃយ៉ាត់ រីជេនស៊ី ភ្នំពេញ។

សិក្ខាសាលាថ្នាក់តំបន់នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ និងពង្រឹងសមត្ថភាពរបស់និយ័តករទីផ្សារមូលធនអាស៊ាន ពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្អែកលើហានិភ័យ រួមទាំងហានិភ័យអាកាសធាតុ តាមរយៈការចែករំលែកបទពិសោធន៍ក្នុងចំណោមសមាជិក ACMF និងអ្នកជំនាញលើការកំណត់ហានិភ័យ ការវាយតម្លៃ និងបច្ចេកទេសផ្តល់អាទិភាពលើការត្រួតពិនិត្យផ្អែកលើហានិភ័យ។

ថ្លែងក្នុងសិក្ខាសាលានេះ ឯកឧត្តម **ស៊ូ សុជាតិ** បានមានប្រសាសន៍ថា៖ *"ការត្រួតពិនិត្យផ្អែកលើហានិភ័យ (RBS) គឺជាត្រីវិស័យសម្រាប់ទីផ្សារមូលធនអាស៊ាន ដែលតម្រង់ទិសមិនត្រឹមតែផ្តោះទៅកាន់អនុលោមភាពប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តោះទៅកេភាពធន់នឹងហានិភ័យជាសកល ផងដែរ។ អភិក្រមនេះ តម្រូវឱ្យមានធនធានត្រួតពិនិត្យដែលផ្តើតសំខាន់ក្នុងការធានាបាននូវប្រតិបត្តិការទីផ្សារ និងកិច្ចគាំទ្រផ្នែកអភិបាលកិច្ចច្បាស់លាស់ ដើម្បីកំណើនប្រកបដោយចីរភាពបន្តក្នុងចំណោមរដ្ឋជាសមាជិក។ តាមរយៈការផ្តល់អាទិភាពដល់ស្ថិរភាព និងសុចរិតភាពរយៈពេលវែង RBS ជាច្រកដែលផ្តល់នូវមូលធនប្រកបដោយប្រសិទ្ធភាព ដែលអាចឱ្យទីផ្សារនៅតែបន្តមានភាពធន់ និងឆ្លើយតបបានទាន់ពេលចំពោះបញ្ហាប្រឈមដែលកំពុងតែវិវត្ត។ ការផ្តោតសំខាន់របស់អភិក្រមនេះ គឺជាមូលដ្ឋានគ្រឹះក្នុងការជំរុញតម្រូវការការវិនិយោគ សម្រាប់សមាហរណកម្ម និងចីរភាពសេដ្ឋកិច្ចអាស៊ាន"*។

ព្រមជាមួយគ្នានេះ លោក Vijay Kumar Akasaam បានសង្កត់ធ្ងន់ថា៖ ***"កិច្ចសហការផ្នែកហិរញ្ញវត្ថុរវាងអ្នករៀបចំគោលនយោបាយ និងនិយ័តករ នៅក្នុងតំបន់អាស៊ាន មានសារៈសំខាន់ក្នុងការជំរុញការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព សម្រាប់ទីផ្សារមូលធនអាស៊ានឆ្ពោះទៅកេភាពធន់ បរិយាបន្ន និងចីរភាព"*****។**

សិក្ខាសាលាថ្នាក់តំបន់ដែលមានរយៈពេល ២ ថ្ងៃនេះ មានសមាសភាពចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.ម.ក.**, មន្ត្រីជាន់ខ្ពស់មកពីសមាជិក ACMF ព្រមទាំងវាគ្មិនជាអ្នកជំនាញនៃសមាជិក ACMF, ADB, មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF), អង្គការគណៈកម្មការមូលបត្រអន្តរជាតិ (IOSCO), អាជ្ញាធរមូលបត្រ និងទីផ្សារអឺរ៉ុប (ESMA) និងវិទ្យាស្ថានហិរញ្ញវត្ថុប្រកបដោយចីរភាពអាស៊ី (SFIA) ដោយមានអ្នកចូលរួមផ្ទាល់ ចំនួន ៦០ រូប និងតាមប្រព័ន្ធអនឡាញ ចំនួន ២២ រូប។ សិក្ខាសាលានេះ បានប្រព្រឹត្តទៅដោយរលូន និងប្រកបដោយផ្លែផ្កាខ្ពស់៕

៙៙❀៚៚